## ក្រសួងមុខងារសាធារណៈ
## គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# របាយការណ៍វឌ្ឍនភាព
# ប្រចាំឆ្នាំ២០១៧
# ស្តីពី
# ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

ខែមីនា ឆ្នាំ២០១៨

# មាតិកា


ទំព័រ

ផ្នែកទី១. សេចក្តីផ្តើម………………………………………………………………………. ៣

ផ្នែកទី២. ការកែលម្អគុណភាពសេវាសាធារណៈ……………………………………………. ៤

ផ្នែកទី៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ន………………………… ១០

ផ្នែកទី៤. ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត…………………….. ២២

ផ្នែកទី៥. យន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ…………………………….. ២៥

ផ្នែកទី៦. យន្តការអនុវត្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃ…………………………. ២៧

ផ្នែកទី៧. បញ្ហាប្រឈមនៅក្នុងការអនុវត្ត……………………………………………………. ៣០

ផ្នែកទី៨. ទិសដៅការងារជាយុទ្ធសាស្ត្រ…………………………………………………. ៣១

បញ្ជីតារាង ទំព័រ


- តារាងទី១៖ ការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលមានលក្ខណៈជាប្រព័ន្ធតាមរយៈសាលាភូមិន្ទរដ្ឋបាល ១២
- តារាងទី២៖ ការរៀបចំមុខតំណែងសំខាន់ៗជូនមន្ត្រីរាជការស៊ីវិល ១៣
- តារាងទី៣៖តារាងស្ថិតិមន្ត្រីរាជការស៊ីវិលជាស្ត្រីសរុបនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ១៨
- តារាងទី៤៖តារាងស្ថិតិមន្ត្រីរាជការស៊ីវិលជាស្ត្រីដែលមានមុខតំណែងនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ១៩
- តារាងទី៥៖តារាងស្ថិតិមន្ត្រីរាជការស៊ីវិលដែលមានកាន់មុខតំណែងគ្រប់គ្រងនៅតាមរាជធានីខេត្តនិងស្ថាប័នផ្សេងទៀត ២០
- តារាងទី៦៖ការដំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន ២២
- តារាងទី៧៖បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ ២២
- តារាងទី៨៖ ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សាគ្រប់ប្រភេទនិងមន្ត្រីភូមិ ២៣
- តារាងទី៩៖ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងសុខាភិបាល ២៣
- តារាងទី១០៖របបសន្តិសុខសង្គមអប្បបរមាប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន ២៣

# ផ្នែកទី១. សេចក្តីផ្តើម

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈ ដែលជាសេនាធិការឱ្យរាជរដ្ឋាភិបាល មានតួនាទីភារកិច្ចនៅក្នុងការរៀបចំ សម្របសម្រួល និងជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។ កម្មវិធីជាតិនេះ គឺផ្តោតជាសំខាន់ទៅលើ៖ (១)សេវាសា-ធារណៈប្រកបដោយគុណភាព ភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា (២)ការគ្រប់គ្រង និងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និង ភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ ដោយប្រកាន់ខ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ (៣)ប្រព័ន្ធបៀវត្សត្រូវធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

ដើម្បីសម្រេចបានជោគជ័យលើការអនុវត្តកម្មវិធីកំណែទម្រង់នេះ គឺទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ទាំងក្របខណ្ឌថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយប្រកាន់ខ្ជាប់នូវភាពជាម្ចាស់ ភាពជាអ្នកដឹកនាំឈរលើអភិក្រមបុរេសកម្មចំពោះការងារ ដោយត្រូវសហការគ្នាដែលមានលក្ខណៈជាស្ថាប័ននិងប្រទាក់ក្រឡាក្នុងស្មារតីនៃការប្រមូលផ្តុំនូវធនធានសម្ភារៈថវិកានិងបញ្ញាញាណ ដើម្បីសម្រេចបានលទ្ធផលរួមដែលជាប្រយោជន៍ដល់មន្ត្រីរាជការនិងប្រជាពលរដ្ឋ។ ក្នុងបរិបទនេះ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងជាអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ បានជំរុញការអនុវត្ត និងការតាមដានត្រួតពិនិត្យនៃការអនុវត្តសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈដែលបានដាក់ចេញជាព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ និងសេចក្តីសម្រេចផ្សេងៗរបស់រាជរដ្ឋាភិបាល និងក្រសួងមុខងារសាធារណៈដោយសហការជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ជារួមការអនុវត្តសកម្មភាព នៅក្នុងឆ្នាំ២០១៧នេះ ក្រសួងមុខងារសាធារណៈ គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ បានខិតខំបំពេញភារកិច្ច តាមស្មារតីនៃភាពជាម្ចាស់ និងអនុវត្តសម្រេចបាននូវវឌ្ឍនភាពការងារជាវិជ្ជមាន បើទោះបីជាមានបញ្ហាប្រឈមមួយចំនួនដែលជួបប្រទះយ៉ាងណាក៏ដោយ។ ក្នុងផ្នែកបន្ទាប់ នឹងមានបង្ហាញពីវឌ្ឍនភាពការងារធៀបនឹងចង្កោមសកម្មភាព យន្តការសម្របសម្រួលជំរុញការអនុវត្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងឆ្នាំ២០១៧ ព្រមទាំងទិសដៅការងារជាយុទ្ធសាស្ត្រសម្រាប់ជំហានបន្ត។

# ផ្នែកទី២. ការកែលម្អគុណភាពសេវាសាធារណៈ

ការកែលម្អគុណភាពសេវាសាធារណៈដែលបានកំណត់ក្នុងផែនការសកម្មភាពនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨មានចង្កោមសកម្មភាពចំនួន០៧។ ក្នុងចំណោមចង្កោមសកម្មភាពទាំង០៧នេះ ចង្កោមសកម្មភាពទី០៤ បានអនុវត្តរួចរាល់នៅក្នុងឆ្នាំ២០១៥ និង២០១៦រួចមកហើយ។ នៅក្នុងឆ្នាំ ២០១៧នេះ ចង្កោមសកម្មភាពដែលត្រូវអនុវត្តបន្តគឺមានចំនួន ០៦ ចង្កោមសកម្មភាព។ វឌ្ឍនភាពនៃចង្កោមសកម្មភាពទាំង ០៦ នោះ មានដូចខាងក្រោម ៖

| ចង្កោមសកម្មភាព | វឌ្ឍនភាពការងារ |
|---|---|
| ១.១ រៀបចំបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | ក្នុងក្របខណ្ឌនៃការអនុវត្តចង្កោមសកម្មភាពនេះ អនុក្រឹត្យស្តីពីការវាយតម្លៃនិងផ្តល់រង្វាន់អង្គភាពផ្តល់សេវាសាធារណៈគំរូត្រូវបានរៀបចំនិងកំពុងឆ្លងការពិភាក្សាកម្រិតបច្ចេកទេសផ្ទៃក្នុង។<br>អនុក្រឹត្យនេះ មានគោលបំណងជំរុញអោយមានការរៀបចំប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈនៅក្នុងផ្ទៃក្នុងក្រសួងស្ថាប័ន និងក្នុងក្របខ័ណ្ឌនៃរដ្ឋបាលសាធារណៈទាំងមូល។ អនុក្រឹត្យនេះ នឹងជំរុញចលនាកែលម្អការផ្តល់សេវាសាធារណៈនៅតាមក្រសួងស្ថាប័ន ប៉ុន្តែនឹងត្រូវចាប់ផ្តើមពីក្រសួងស្ថាប័នអាទិភាពចំនួន០២ គឺក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។ |
| **វិធានការអនុវត្តបន្ត**<br>*ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ គួររៀបចំឱ្យមានការពិគ្រោះយោបល់ជាលក្ខណៈអន្តរក្រសួងចង្អៀតតាមវិស័យនីមួយៗ ដើម្បីរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ គុណភាពសេវាសាធារណៈដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ នឹងអាចទទួលយកមកអនុវត្តបានសម្រាប់ធ្វើជាម៉ែត្រវាស់ក្នុងការជំរុញនិងកែលម្អគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។* | |
| ១.២ ការធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈ ព្រមទាំងជំរុញការបណ្តុះបណ្តាលនិងផ្សព្វផ្សាយអំពីសេវាសាធារណៈជាពិសេសតាមប្រព័ន្ធអេឡិចត្រូនិច | ក្នុងក្របខណ្ឌនៃការធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានស្តីពីសេវាសាធារណៈ ព័ត៌មានស្តីពីសេវាសាធារណៈរបស់ក្រសួងស្ថាប័នត្រូវបានប្រមូលនិងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ទាំងនៅក្នុងកម្រងព័ត៌មានសេវាសាធារណៈ និងបានដាក់បញ្ចូលក្នុងកម្មវិធីការផ្តល់ព័ត៌មានសេវាសាធារណៈ តាមទូរស័ព្ទស្មាតហ្វូន(Public Service |

<table>
<tr><td></td><td>Mobile Application)។ ព័ត៌មាន ដែលត្រូវបានធ្វើបច្ចុប្បន្នភាព រួមមាន ព័ត៌មានអំពីស្តង់ដាសេវាសាធារណៈ (តម្លៃ រយៈពេល នៃការទទួលយកសេវា និងឯកសារតម្រូវ ព្រមទាំងមធ្យោបាយ នៃទំនាក់ទំនងនិងផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា។<br><br>ទន្ទឹមនឹងការប្រមូលព័ត៌មាន និងធ្វើបច្ចុប្បន្នភាពកម្រងព័ត៌មានស្តីពីសេវាសាធារណៈ ការផ្សព្វផ្សាយ អំពីរបៀបនៃការប្រើប្រាស់កម្រងព័ត៌មានសេវាសាធារណៈ និងកម្មវិធីផ្តល់ព័ត៌មានស្តីពីសេវាសាធារណៈក៏ត្រូវបានអនុវត្ត ដើម្បីផ្សព្វផ្សាយដល់មន្ត្រីរាជការ និងសាធារណជនផងដែរ ក្នុងកំឡុងពេលនៃការផ្តល់ការបណ្តុះបណ្តាលស្តីពីសេវាសាធារណៈ ដល់មន្ត្រីចំនួនប្រមាណ ២០០ នាក់ និងផ្សព្វផ្សាយតាមរយៈស្ថានីយទូរទស្សន៍ក្នុងស្រុក។</td></tr>
<tr><td colspan="2">វិធានការអនុវត្តបន្ត<br><br>ការធ្វើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈរបស់ក្រសួង ស្ថាប័នទាំងអស់តាមរយៈព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន ឬគេហទំព័ររបស់ក្រសួងមុខងារសាធារណៈ គួរត្រូវរៀបចំឱ្យមានការផ្សព្វផ្សាយ និងបណ្តុះបណ្តាលឱ្យបានទូលំទូលាយដើម្បីបញ្ជ្រាបដល់អ្នកផ្តល់សេវា និងអ្នកទទួលសេវាសំដៅយល់ដឹងពីការផ្តល់សេវាធារណៈ ដែលបានធ្វើបច្ចុប្បន្នកម្ម ឈានទៅដល់ការផ្តល់សេវាត្រឹមត្រូវតាមគោលការណ៍ដែលបានកំណត់។</td></tr>
<tr><td>១.៣ កែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសាធារណៈសំខាន់ៗដែលពាក់ព័ន្ធផ្ទាល់នឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ</td><td>ដើម្បីជំរុញការកែលម្អនីតិវិធីនិងពង្រីការអនុវត្តយន្តការមានប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ សកម្មភាពសំខាន់ចំនួន ០៣ ត្រូវបានអនុវត្ត៖<br>- សកម្មភាពទី១ គឺការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីទស្សនទាននៃការកែលម្អការផ្តល់សេវាសាធារណៈដែលត្រូវបានអនុវត្តជាបន្តបន្ទាប់ទាំងក្នុងក្របខ័ណ្ឌនៃសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ (ធនាគារពិភពលោក) និងក្របខណ្ឌនៃថវិកាជាតិ។<br>- សកម្មភាពទី២ គឺការរៀបចំច្បាប់ស្តីពីសេវាសាធារណៈ ដែលនឹងក្លាយជាឧបករណ៍គតិយុត្តិសម្រាប់កែលម្អនីតិវិធីនៃការផ្តល់សេវាសាធារណៈ និងជំរុញលើកទឹកចិត្តការអនុវត្តគំនិតផ្តួចផ្តើមថ្មីៗក្នុងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងប្រសិទ្ធផល។<br>- សកម្មភាពទី៣ គឺការចុះត្រួតពិនិត្យ និងផ្តល់អនុសាសន៍កែលម្អនីតិវិធី និងការអនុវត្តការកែលម្អការផ្តល់សេវា</td></tr>
</table>

| | |
|---|---|
| | សាធារណៈដែលប៉ះពាល់ផ្ទាល់នឹងជីវភាពប្រជាពលរដ្ឋ។ ក្នុងនោះក្រសួង ស្ថាប័ន និងអង្គភាពផ្តល់សេវានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានចុះត្រួតពិនិត្យ ដូចជាអង្គភាពចំណុះទីស្តីការក្រសួងពាណិជ្ជកម្ម និងមន្ទីរពាណិជ្ជកម្ម រាជធានីភ្នំពេញ កោះកុង កំពង់ចាម និងបាត់ដំបង។ ក្នុងការត្រួតពិនិត្យនោះ គឺផ្តោតលើសេវាចំនួន០៣ (១)សេវាចេញលិខិតអនុញ្ញាតប្រកប អាជីវកម្មសេវាកម្មពាណិជ្ជកម្ម (២)សេវាចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហៈធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការ និង(៣)សេវាចេញលិខិតអនុញ្ញាតបិទស្លាកលើមុខទំនិញ និងសេវាកម្មរូបិយប័ណ្ណបរទេស និងផ្អែកលើសូចនាករដែលបានកំនត់។ |

**វិធានការអនុវត្តបន្ត៖**

*នៅក្នុងការអនុវត្តសកម្មភាពនេះ ក្រុមការងារ គួរបន្តការចុះត្រួតពិនិត្យលើស្ថានភាពការអនុវត្តនៃការផ្តល់សេវាសាធារណៈដែលពាក់ព័ន្ធផ្ទាល់ទៅនឹងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាប្រចាំទាំងក្របខណ្ឌថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់ពីសូចនាករ ពេលវេលានៃការអនុវត្ត និងអង្គភាពដែលត្រូវចុះត្រួតពិនិត្យ សំដៅផ្តល់មតិយោបល់ដើម្បីកែលម្អនីតិវិធីនៃការផ្តល់សេវា។*

*ទន្ទឹមនេះ ក្រុមការងារ គួររៀបចំការផ្សព្វផ្សាយនូវក្របខណ្ឌច្បាប់គតិយុត្ត គោលនយោបាយ និងទស្សនទាននៃការផ្តល់សេវាសាធារណៈជូនដល់គ្រប់ភាគីពាក់ព័ន្ធនៅក្នុងការផ្តល់សេវានិងប្រើប្រាស់សេវា ជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ។*

| | |
|---|---|
| ១.៤ ធ្វើការវិភាគមុខងារនិងរំហូរការងារសម្រាប់សេវាសាធារណៈដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មន្ត្រីរាជការស៊ីវិល | ការអនុវត្តចង្កោមសកម្មភាពនេះ សម្រេចបានលទ្ធផលពេញលេញដោយបានកែលម្អនីតិវិធីនៃការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារ ដោយទទួលបានបៀវត្សនៅក្នុងសប្តាហ៍ទី០៤ នៃខែ។ ទន្ទឹមនេះ ក្រុមការងារ ក៏បានកែលម្អនូវនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ហើយប្រាក់ឧបត្ថម្ភរបស់មន្ត្រីដែលចូលនិវត្តន៍ ក៏ទទួលបានព្រមពេលជាមួយគ្នានោះដែរ។<br><br>ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយធានារ៉ាប់រងសុខាភិបាលជូនមន្ត្រីរាជការ។ |
| ១.៥ កែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវាសាធារណៈ ដែលអនុវត្តដោយស្ថាប័នមានសមត្ថកិច្ច ឬ ស្ថាប័នទទួល | យន្តការនៃការផ្តល់សេវាសាធារណៈដែលត្រូវបានដាក់ឱ្យអនុវត្តស្របតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ត្រូវបានពិនិត្យនិងផ្តល់អនុសាសន៍ពង្រឹងប្រសិទ្ធភាពនៃការអនុវត្ត |

| | |
|---|---|
| សមត្ថកិច្ច តាមរយៈយន្តការផ្សេងៗ ដូចជា ទីភ្នាក់ងារប្រតិបត្តិការពិសេស ច្រកចេញចូលតែមួយ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ | និងពង្រីកការអនុវត្តនៅក្នុងក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ក្នុងនោះរួមមាន៖<br>(១)ការអនុវត្តយន្តការ ច្រកចេញចូលតែមួយ ត្រូវបានពង្រីកការអនុវត្តដល់ចំនួន៥២ ការិយាល័យ នៅគ្រប់ក្រុង ខណ្ឌ និងបណ្តាស្រុកមួយចំនួន ។<br>(២)ការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងក្រសួងសុខាភិបាល និង ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានពង្រីកការអនុវត្តជាលំដាប់ ក្នុងនោះរួមមាន៖<br>- ក្រសួងសុខាភិបាលបានដាក់ឱ្យអនុវត្តនូវយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស នៅខេត្តគោលដៅចំនួន១៦ រួមមាន៖ ខេត្តតាកែវ ព្រៃវែង កំពង់ចាម រតនគិរី មណ្ឌលគិរី សៀមរាប ឧត្តរមានជ័យ ព្រះវិហារ កោះកុង ស្ទឹងត្រែង ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ ក្រចេះ កំពត កំពង់ធំ បានចំនួន ៤០ ក្នុងនោះរួមមាន៖<br>- មន្ទីរពេទ្យបង្អែកខេត្ត ចំនួន១៤<br>- ការិយាល័យសុខាភិបាលស្រុក ចំនួន ២៦<br>- មន្ទីរពេទ្យបង្អែកស្រុក ចំនួន ២០<br>- មណ្ឌលសុខភាព ចំនួន ៣៥៤<br>- ប៉ុស្តិ៍សុខភាព ចំនួន ៧៩។<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដាក់ឱ្យអនុវត្តយន្តការទីភ្នាក់ងារជាតិមុខរបរបនិងការងារដែលមានមជ្ឈមណ្ឌលការងារនៅទីតាំងនៅ៖ រាជធានីភ្នំពេញ ខេត្តបាត់ដំបង សៀមរាប កំពត ស្វាយរៀង និងតាកែវ។ |

### វិធានការអនុវត្តបន្ត

*បន្តចុះត្រួតពិនិត្យលើស្ថានភាពនៃការអនុវត្តយន្តការនៃការផ្តល់សេវាសាធារណៈ ក្នុងនោះរួមមាន យន្តការច្រកចេញចូលតែមួយ ទីភ្នាក់ងារប្រតិបត្តិការពិសេស គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ សំដៅពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការនីមួយៗ។*

*នៅក្នុងការអនុវត្តនូវយន្តការនីមួយៗ គួររៀបចំឱ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃឱ្យបានច្បាស់លាស់ ដោយមានការកំណត់ពីសូចនាករឱ្យជាក់លាក់សម្រាប់ធ្វើការវាស់វែងពីប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ។*

| | |
|---|---|
| ១.៦ រៀបចំដាក់ឱ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា | សកម្មភាពចំនួន០២ ត្រូវបានអនុវត្តលើចង្កោមសកម្មភាពនេះ គឺការបណ្តុះបណ្តាលអំពីយន្តការផ្តល់ព័ត៌មានត្រឡប់និងបណ្តឹងតវ៉ា និងត្រួតពិនិត្យលើយន្តការទទួលព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់ក្រសួង ស្ថាប័ន។<br><br>ក្នុងក្របខ័ណ្ឌនៃការបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលចំនួន ០៦ ត្រូវបានរៀបចំឡើងជូនដល់ក្រសួង ស្ថាប័ន និងអង្គភាពផ្តល់សេវាថ្នាក់ក្រោមជាតិ សំដៅពង្រឹងការអនុវត្តយន្តការទទួល និងដោះស្រាយព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា ( វគ្គបណ្តុះបណ្តាលចំនួន ០៤ ដល់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន និងក្រសួងបរិស្ថាន និងចំនួន០២ ផ្សេងទៀត ត្រូវបានអនុវត្តដោយមានការគាំទ្រហិរញ្ញប្បទានពីធនាគារពិភពលោកសម្រាប់អន្តរក្រសួង។<br><br>សម្រាប់ការពិនិត្យលើយន្តការទទួលព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់ក្រសួង ស្ថាប័ន គ្រប់លេខទូរស័ព្ទ និងគេហទំព័ររបស់អង្គភាពផ្តល់សេវាសាធារណៈ ត្រូវបានត្រួតពិនិត្យនិងបញ្ជាក់អំពីការដំណើរ និងបានរកឃើញនូវភាពអសកម្មមួយចំនួនដូចជា ការមិនដំណើរការ ការមិនឆ្លើយតប និងការឆ្លើយដោយមិនប្រើអកប្បកិរិយាជាអ្នកផ្តល់សេវា។ |

### វិធានការអនុវត្តបន្ត

*បន្តការផ្សព្វផ្សាយ និងជំរុញការដាក់ឱ្យដំណើរការយន្តការទទួលនិងដោះស្រាយព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា ព្រមទាំងបន្តការពិនិត្យជារើយៗលើយន្តការដែលមានស្រាប់ដើម្បីធានាដល់ដំណើរការនិងប្រសិទ្ធភាពនៃការអនុវត្តយន្តការនេះ។*

| | |
|---|---|
| ១.៧ សិក្សា និងជំរុញការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា | លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាល បានបញ្ជ្រាបទស្សនទាននិងការលើកទឹកចិត្តដល់ក្រសួង ស្ថាប័ន ក្នុងការអនុវត្តការផ្តល់សេវាសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា តាមរយៈការធ្វើបទបង្ហាញនៅក្នុងការបណ្តុះបណ្តាលនិងសិក្ខាសាលាស្តីពីសេវាសាធារណៈ។<br>លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលបានចុះអនុស្សារណៈស្តីពីការឃោគយល់គ្នាជាមួយអង្គការតម្លាភាពកម្ពុជាដើម្បីរៀបចំនិងដាក់ឱ្យដំណើរការច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)។ |

### វិធានការអនុវត្តបន្ត

*ក្រុមការងារ ត្រូវបន្តប្រមូលទិន្នន័យស្តីពីការផ្តល់សេវាសាធារណៈ និងដាក់ឱ្យដំណើរការជាផ្លូវការនូវច្រកទ្វារអេឡិចត្រូនិចផ្តល់ព័ត៌មានសេវាសាធារណៈ (Public Service Gateway)។ ជាមួយគ្នានេះ ត្រូវរៀបចំបន្តផ្សព្វផ្សាយអំពីសារប្រយោជន៍នៃព័ត៌មានវិទ្យាសម្រាប់ការផ្តល់ សេវាសាធារណៈ។ បន្ថែមលើសពីនេះ ក្រុមការងារត្រូវផ្តល់ការសហការនិងកៀងគរធនធាន ទាំងបច្ចេកទេសនិងហិរញ្ញវត្ថុ ព្រមទាំងរៀបចំ ឱ្យមានការលើកទឹកចិត្តដល់ការអង្គភាពដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្តល់សេវាសាធារណៈ។*

# ផ្នែកទី៣. ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស និងស្ថាប័ន

ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនិងស្ថាប័ន ដែលបានកំណត់ក្នុងផែនការសកម្មភាពនៃកម្មវិធី ជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ បានដាក់ចេញចង្កោមសកម្មភាពចំនួន០៧ ដោយក្នុងនោះ ចង្កោមសកម្មភាពទី៤ បានអនុវត្តរួចរាល់នៅក្នុងឆ្នាំ២០១៥រួចមកហើយ។ នៅក្នុងឆ្នាំ ២០១៧នេះ ចង្កោមសកម្មភាពចំនួន០៦ ត្រូវបានអនុវត្ត និងទទួលបាននូវវឌ្ឍនភាពការងារ ដូចខាងក្រោម៖

***ចង្កោមសកម្មភាព២.១៖ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគតិយុត្តនៃការបណ្តុះបណ្តាលជាកាតព្វកិច្ចសម្រាប់មន្ត្រីរាជការស៊ីវិល និងកែលម្អកម្មវិធីបណ្តុះបណ្តាល និងការអភិវឌ្ឍធនធានមនុស្សនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***



*ប្រភព៖ សាលាភូមិន្ទរដ្ឋបាល, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៧ សន្និសិទភាពជាអ្នកដឹកនាំស្តីពីការដឹកនាំជាយុទ្ធសាស្ត្រ ការអភិវឌ្ឍមូលធនមនុស្ស និងការប្រមើលមើលទៅថ្ងៃអនាគត*



*ប្រភព: សាលាភូមិន្ទរដ្ឋបាល, វគ្គបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ ២០១៧*

នៅក្នុងក្របខណ្ឌនៃការបណ្តុះបណ្តាលជាកាតព្វកិច្ច ក្រសួងមុខងារសាធារណៈ សាលាភូមិន្ទរដ្ឋបាល បានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីសាធារណៈនៃប្រទេសសិង្ហបុរី និងមូលនិធិអន្តរជាតិ (Temasek Foundation) រៀបចំសន្និសិទ្ធនៃភាពជាអ្នកដឹកនាំស្តីពី "ការដឹកនាំជាយុទ្ធសាស្ត្រ ការអភិវឌ្ឍមូលធនមនុស្ស និងការប្រមើលមើលទៅថ្ងៃអនាគត" នាថ្ងៃទី២៦-២៧ ខែតុលា ឆ្នាំ២០១៧ ដែលមានសិក្ខាកាមសរុបចំនួន ២៥០នាក់ កម្រិតថ្នាក់អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងអភិបាលខេត្ត និងសិក្ខាសាលាចំនួន០២ សម្រាប់មន្ត្រីរាជការជាន់ខ្ពស់ស្តីពី "ការផ្តល់សេវាសាធារណៈល្អប្រសើរ និងការគ្រប់គ្រងការផ្លាស់ប្តូរ" ថ្ងៃទី២៧ ខែវិច្ឆិកា ដល់ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០១៧ ដែលមានសិក្ខាកាមសរុបចំនួន ៩៤នាក់ (ថ្នាក់អនុរដ្ឋលេខាធិការ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ និងអភិបាលខេត្ត) ក្នុងនោះ ស្ត្រី១៧រូប និងអភិបាលរាជធានីខេត្តសរុបចំនួន១៩រូប។ សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង៣ សំខាន់ៗ គឺៈ (១)អភិវឌ្ឍសមត្ថភាពជាអ្នកដឹកនាំ (២)ពង្រឹងសមត្ថភាពផ្តល់សេវាសាធារណៈ និង(៣)ជំរុញឱ្យមានការផ្សារភ្ជាប់ទំនាក់ទំនងនិងផ្លាស់ប្តូរទស្សនទានរវាងមន្ត្រីជំនាញជាន់ខ្ពស់សិង្ហបុរី និងមន្ត្រីជាន់ខ្ពស់កម្ពុជា។

តារាងទី១ខាងក្រោមនេះ នឹងបង្ហាញពីចំនួនមន្ត្រីរាជការស៊ីវិលដែលទទួលបានការបណ្តុះបណ្តាលមានលក្ខណៈជាប្រព័ន្ធ ដែលធ្វើឡើងតាមរយៈសាលាភូមិន្ទរដ្ឋបាល។ ដោយគិតចាប់តាំងពីឆ្នាំ២០១៣ រហូតដល់ត្រឹមឆ្នាំ២០១៧ សរុបចំនួន ៣.៦៥៣ រូប ក្នុងនោះរួមមាន៖ ការបណ្តុះបណ្តាលសិស្សមន្ត្រីជាន់ខ្ពស់ សិស្សមន្ត្រីក្រមការ មន្ត្រីរាជការជ្រើសរើសថ្មីនៃ ក្រសួងស្ថាប័នថ្នាក់ជាតិ កម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់និងមធ្យម ជំនាញឯកទេសរយៈពេលខ្លី វគ្គបណ្តុះបណ្តាលមន្ត្រីរាជការនៃក្រសួងបរិស្ថាន វគ្គបណ្តុះបណ្តាលថ្នាក់ដឹកនាំជាស្ត្រីជារដ្ឋលេខាធិការនិង អនុរដ្ឋលេខាធិការ វគ្គបណ្តុះបណ្តាលមន្ត្រីជាន់ខ្ពស់ជាអនុរដ្ឋលេខាធិការ អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ និងអភិបាលរាជធានី ខេត្ត ព្រមជាមួយវគ្គបណ្តុះបណ្តាលគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សារាជធានីភ្នំពេញ នៃក្រសួងអប់រំ យុវជន និងកីឡា។

តារាងទី១៖ ការបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលមានលក្ខណៈជាប្រព័ន្ធតាមរយៈសាលាភូមិន្ទរដ្ឋបាល

| ឆ្នាំ / **វគ្គបណ្តុះបណ្តាល** | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | សរុប |
|---|---|---|---|---|---|---|
| សិស្សមន្ត្រីជាន់ខ្ពស់ | - | ៦០ | - | ៥៦ | ៦០ | ១៧៦ |
| សិស្សមន្ត្រីក្រមការ | ៦១ | - | ៥៥ | - | ១០១ | ២១៧ |
| មន្ត្រីរាជការជ្រើសរើសថ្មីនៃក្រសួងស្ថាប័នថ្នាក់ជាតិ | - | - | - | - | ៦១៩ | ៦១៩ |
| មន្ត្រីរាជការជ្រើសរើសថ្មីនៃក្រសួងបរិស្ថាន | - | - | - | - | ៧៥ | ៧៥ |
| កម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ | ៩៩ | ៩៥ | ១១៥ | ៣៧១ | ៣១០ | ៩៩០ |
| កម្មសិក្សាការីវគ្គវិក្រឹត្យការមន្ត្រីមធ្យម | ៧០ | ៨២ | ៨៣ | ១១៧ | ១០៨ | ៤៦០ |
| ជំនាញឯកទេសរយៈពេលខ្លី | - | ៤០ | ២៤ | - | - | ៦៤ |
| មន្ត្រីរាជការនៃក្រសួងបរិស្ថាន | - | - | ៦៦ | ២២ | ៦៥ | ១៥៣ |
| ថ្នាក់ដឹកនាំជាស្ត្រីជារដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ | - | - | - | ៨៤ | - | ៨៤ |
| មន្ត្រីជាន់ខ្ពស់ជា អគ្គនាយក អគ្គាធិការ អគ្គលេខាធិការ និងអភិបាលរាជធានី ខេត្ត | - | - | - | ១៦៦ | - | ១៦៦ |
| មន្ត្រីជាន់ខ្ពស់ជាអនុរដ្ឋលេខាធិការអគ្គនាយក អគ្គាធិការ អគ្គលេខាធិការ និងអភិបាលរាជធានី ខេត្ត | - | - | - | - | ៣៤៤ | ៣៤៤ |
| គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សារាជធានីភ្នំពេញ កអយក | - | - | - | - | ២៥៧ | ២៥៧ |
| មគ្គុទ្ទេសទេសចរណ៍ | - | - | ៤៨ | - | - | ៤៨ |
| | | | | | **សរុបរួម** | **៣.៦៥៣** |

***ចង្កោមសកម្មភាព២.២ រៀបចំអង្គមន្ត្រីរាជការស៊ីវិល មុខតំណែង និងការពិព័ណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ***

ផ្អែកលើគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្សទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គោលការណ៍រួមនៃការគ្រប់គ្រងមុខងារសាធារណៈរបស់រដ្ឋ និងការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈ បានរៀបចំនិងដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត និងយុទ្ធសាស្ត្រសំខាន់ៗសម្រាប់ពង្រឹងការគ្រប់គ្រងធនធានមនុស្ស រួមទាំងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័នទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដោយកំណត់ឱ្យមានការរៀបចំការរៀបចំអង្គវិជ្ជាជីវៈ ការកំណត់ចំនួនមុខតំណែងគ្រប់គ្រង និងការពិពណ៌នា

មុខតំណែងក្នុងរដ្ឋបាលសាធារណៈកម្ពុជា។ ក្នុងការអនុវត្តចង្កោមសកម្មភាពនេះ ជាវឌ្ឍនភាពការងារសម្រេចបាន មានដូចជា៖

ទី១. បានរៀបចំដាក់ចេញនូវសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីអង្គវិជ្ជាជីវៈ(អង្គរដ្ឋបាល)

ទី២. បានរៀបចំកំណត់នូវចំនួនមុខតំណែងសំខាន់ៗសម្រាប់មន្ត្រីរាជការស៊ីវិល និងការពិពណ៌នាមុខតំណែងរបស់ក្រសួងស្ថាប័នថ្នាក់ជាតិ ដូចខាងក្រោម៖

នៅក្នុងតារាងទី២ នឹងបង្ហាញពីចំនួនមុខតំណែងសំខាន់ៗរបស់មន្ត្រីរាជការស៊ីវិល គិតចាប់ពី កម្រិតមុខតំណែងអគ្គលេខាធិការ រហូតដល់កម្រិតអនុប្រធានការិយាល័យសម្រាប់ក្រសួងស្ថាប័នថ្នាក់ជាតិ។ ដោយឡែក ថ្នាក់ក្រោមជាតិមានកម្រិតមុខតំណែងចាប់ពីប្រធានមន្ទីររាជធានី ខេត្ត រហូតដល់កម្រិតអនុប្រធានការិយាល័យស្រុក ខណ្ឌ ដោយគិតចាប់ពីឆ្នាំ២០១៣ រហូតដល់ឆ្នាំ២០១៧។

តារាងទី២៖ ការរៀបចំមុខតំណែងសំខាន់ៗជូនមន្ត្រីរាជការស៊ីវិល

| លរ | ឆ្នាំ / មុខតំណែង | ២០១៣ ចំនួន | ២០១៤ ចំនួន | ២០១៥ ចំនួន | ២០១៦ ចំនួន | ២០១៧ ចំនួន |
|---|---|---|---|---|---|---|
| ១ | អគ្គលេខាធិការ | ១៩ | ១៦ | ១៣ | ១៩ | ១៥ |
| ២ | អគ្គលេខាធិការរង | ១២៥ | ១២១ | ១៣៦ | ៩៨ | ១០៣ |
| ៣ | អគ្គនាយក | ១៦៣ | ២៤៥ | ៩១ | ៩៧ | ១០៤ |
| ៤ | អគ្គាធិការ | ១៥ | ១២ | ២០ | ២១ | ១៦ |
| ៥ | អគ្គនាយករង | ៤០៦ | ៥៣៣ | ៤៤៥ | ៤៨០ | ៥០៦ |
| ៦ | អគ្គាធិការរង | ៥៨ | ៥២ | ៥២ | ៧៦ | ៨៦ |
| ៧ | ប្រធាននាយកដ្ឋាន | ៥១៣ | ៧០៤ | ៦៦៤ | ៧០៦ | ៧២១ |
| ៨ | អធិការ | ៦១ | ៦២ | ៦៣ | ៧៦ | ៧៩ |
| ៩ | អនុប្រធាននាយកដ្ឋាន | ១.៩៦៤ | ២.២៦៣ | ២.៤៤០ | ២.៥៩៤ | ២.៧៦០ |
| ១០ | ប្រធានការិយាល័យ | ២.២៦១ | ២.២៤៥ | ២.៧៤៤ | ៣.០៤៣ | ៣.១៥២ |
| ១១ | អនុប្រធានការិយាល័យ | ២.២៨៩ | ២.១០៧ | ៤.៥៥៩ | ៥.២៤១ | ៥.៤៦៨ |
| ១២ | ប្រធានមន្ទីររាជធានី ខេត្ត | ៤៨៩ | ៥១៤ | ៥៣៥ | ៥៤៣ | ៥៥២ |
| ១៣ | អនុប្រធានមន្ទីររាជធានី ខេត្ត | ១.៣០៩ | ១.២១២ | ១.២៨០ | ១.៣៧៤ | ១.៤០០ |
| ១៤ | ប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ១.៧១១ | ១.៥០៦ | ២.០១៤ | ២.១៣៤ | ២.១៦២ |
| ១៥ | អនុប្រធានការិយាល័យមន្ទីររាជធានី ខេត្ត | ២.៦៧០ | ២.៤៣៨ | ២.៦៩៧ | ២.៧៦៧ | ២.៩៧៥ |
| ១៦ | ប្រធានការិយាល័យស្រុក ខណ្ឌ | ១.៦៣៨ | ១៤៤១ | ១.៣៥៩ | ១.៤៣៨ | ១.៤៤៧ |
| ១៧ | អនុប្រធានការិយាល័យស្រុក ខណ្ឌ | ១.៤៣៥ | ១.៣៣១ | ១.១១៨ | ១.០៤៣ | ៩៩៧ |

*ប្រភព៖ របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ២០១៧និងទិសដៅឆ្នាំ២០១៨របស់ក្រសួងមុខងារសាធារណៈចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧*

ទន្ទឹមនឹងនេះផងដែរ លេខាធិការដ្ឋាននៃគ.ក.រ ក្រសួងមុខងារសាធារណៈ បានរៀបចំសិក្ខាសាលាស្តីពី "ការរៀបចំចងក្រងការពិពណ៌នាមុខតំណែង" នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ដែលមានសមាភាពចូលរួមជាមន្ត្រីរាជការគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ សរុប ចំនួន១៣០រូប ស្រី២០រូប។ ការរៀបចំសិក្ខាសាលានេះ

ក្នុងគោលបំណងដើម្បីពន្លឿនការរៀបចំការពិពណ៌នាមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឱ្យបានបញ្ចប់ទាន់ពេលវេលាដែលបានកំណត់ និងត្រៀមរៀបចំការពិពណ៌នាមុខតំណែងវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការទាំងអស់ក្នុងមុខងារសាធារណៈរបស់ព្រះរាជាណាចក្រកម្ពុជា ។

ជាលទ្ធផលគិតត្រឹមឆ្នាំ ២០១៧នេះ ទើបតែមានក្រសួងស្ថាប័នចំនួន១១ ដែលបានបញ្ចប់ការរៀបចំការពិពណ៌នាមុខតំណែងគ្រប់គ្រង ក្នុងនោះរួមមាន៖

| | | |
|---|---|---|
| ១- | ក្រសួងអប់រំ យុវជន និងកីឡា | មានចំនួន ៦៦ |
| ២- | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | មានចំនួន ២៧០ |
| ៣- | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | មានចំនួន ៣២៨ |
| ៤- | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | មានចំនួន ២១០ |
| ៥- | ក្រសួងកិច្ចការនារី | មានចំនួន ១៤៨ |
| ៦- | ក្រសួងធនធានទឹកនិងឧតុនិយម | មានចំនួន ២១២ |
| ៧- | ក្រសួងពាណិជ្ជកម្ម | មានចំនួន ២៦២ |
| ៨- | ក្រសួងធម្មការនិងសាសនា | មានចំនួន ២៣២ |
| ៩- | ក្រសួងអភិវឌ្ឍន៍ជនបទ | មានចំនួន ១៤៤ |
| ១០- | ទីស្ដីការគណៈរដ្ឋមន្ត្រី | មានចំនួន ៩៣ |
| ១១- | ក្រសួងបរិស្ថាន | មានចំនួន ៤៤០ |

ដោយឡែកសម្រាប់ថ្នាក់ក្រោមជាតិ គឺមានមន្ទីរចំនួន០៨ដែលបានបញ្ចប់ការរៀបចំការពិពណ៌នាមុខតំណែងក្នុងនោះរួមមាន៖ មន្ទីរអប់រំ យុវជន និងកីឡា, មន្ទីរឧស្សហកម្មនិងសិប្បកម្ម, មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ, មន្ទីរកិច្ចការនារី, មន្ទីរធនធានទឹកនិងឧតុនិយម, មន្ទីរពាណិជ្ជកម្ម, មន្ទីរធម្មការនិងសាសនា និងមន្ទីរអភិវឌ្ឍន៍ជនបទ។

***ចង្កោមសកម្មភាព២.៣ ការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងគុណផល និងប្រព័ន្ធលើកទឹកចិត្តនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

នៅក្នុងការអនុវត្តចង្កោមសកម្មភាពនេះ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ សម្រេចបាននូវវឌ្ឍនភាពការងារជាវិជ្ជមាន ដោយរៀបចំនិងសម្រេចនូវឯកសារគោលការណ៍ណែនាំស្ដីពីប្រព័ន្ធគ្រប់គ្រងគុណផលដែលផ្ដោតលើសមាសធាតុសំខាន់ៗចំនួន ០៧ រួមមាន៖ ផែនការការងារប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន ផែនការការងារប្រចាំឆ្នាំរបស់អង្គភាព ការពិពណ៌នាមុខតំណែង លក្ខខណ្ឌការងារ ការគ្រប់គ្រងវត្តមាន របាយការណ៍លទ្ធផលនិងការត្រួតពិនិត្យឡើងវិញ និងការវាយតម្លៃគុណផល។ ជាមួយគ្នានេះដែរ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ បានឯកភាពនិងគ្រោងដាក់ឲ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងគុណផលនៅការិយាល័យច្រកចេញចូលតែមួយនៅ ស្រុក មោងឫស្សី និងក្រុងបាត់ដំបង ខេត្តបាត់ដំបង មុននឹងបន្តទៅអនុវត្តនៅខេត្តសៀមរាប និងខេត្ត កណ្ដាល ។

លើសពីនេះទៅទៀត ដើម្បីឱ្យការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងអាចទទួលយកមកអនុវត្តបានស្របតាមបរិបទតំបន់និងឈានទៅបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឲ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ បានរៀបចំសិក្ខាសាលាអាស៊ានស្តីពី"វេទិកាកសាងសមត្ថភាពមុខងារសាធារណៈអាស៊ាន និងប្រព័ន្ធគ្រប់គ្រងគុណផល" កាលពីថ្ងៃទី០៤-០៦ ខែកញ្ញា ឆ្នាំ២០១៧ ដោយមានកិច្ច សហប្រតិបត្តិការរវាងក្រសួងមុខងារសាធារណៈ និងទីភ្នាក់ងារជាតិមុខងារសាធារណៈនៃប្រទេសឥណ្ឌូនេស៊ី ក្នុងគោលបំណង៖ (១)ដើម្បីឆ្លើយតបទៅសេចក្តីថ្លែងការណ៍អាស៊ានស្តីពីតួនាទីរបស់មុខងារសាធារណៈដែល ជាកត្តាលិករដើម្បីឈានទៅសម្រេចបាននូវទស្សនវិស័យសហគមន៍អាស៊ាន២០២៥ (២)អនុវត្តនូវក្របខណ្ឌផែនការសកម្មភាពរបស់កិច្ចសហប្រតិបត្តិការអាស៊ានស្តីពីកិច្ចការមុខងារសាធារណៈ ២០១៦-២០២០ មានគោលដៅលើកកម្ពស់សមត្ថភាពមន្ត្រីមុខងារសាធារណៈអាស៊ាន ដើម្បីឆ្លើយតបទៅបញ្ហាប្រឈម និងតម្រូវការរបស់ប្រជាជនតាមរយៈកិច្ចសហប្រតិបត្តិការនិងនវានុវត្តន៍ (៣)ប្រមូលធាតុចូលពីអ្នកជំនាញពាក់ព័ន្ធទាំងអស់គ្រប់កម្រិត រួមមាន៖ អ្នករៀបចំគោលនយោបាយ អ្នកបច្ចេកទេស អ្នកគ្រប់គ្រងក្នុងការអនុវត្តការងារពីបណ្តាប្រទេសអាស៊ានទាំងអស់ (៤)អញ្ជើញវាគ្មិននិងអ្នកជំនាញកម្រិតខ្ពស់តំណាងប្រទេសអាស៊ានទាំង ១០ រួមទាំងសាធារណៈរដ្ឋកូរ៉េខាងត្បូង និងអង្គការអន្តរជាតិមួយចំនួន រួមជាមួយនឹងមន្ត្រីរាជការដែលកាន់មុខតំណែងគ្រប់គ្រងបច្ចេកទេសនិងធ្លាប់មានបទពិសោធន៍អនុវត្តផ្ទាល់លើការគ្រប់គ្រងគុណផលនៅតាមក្រសួងស្ថាប័នសំខាន់ៗ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីចែករំលែកចំណេះដឹងនិងបទពិសោធន៍លើការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផល (៥)ផ្តល់មតិយោបល់ និងកែលម្អឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់វិស័យរដ្ឋបាលសាធារណៈឱ្យមានលក្ខណៈទំនើបកម្មស្របតាមបរិបទតំបន់និងកម្ពុជា (៦)ផ្តល់ជាវេទិកាមួយសម្រាប់ចែករំលែកចំណេះដឹង និងបទពិសោធន៍ពីបណ្តាអ្នកជំនាញជាន់ខ្ពស់ដែលមកពីប្រទេសអាស៊ានទាំង១០ និងសាធារណៈរដ្ឋកូរ៉េខាងត្បូងសម្រាប់ការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ សំដៅលើកកម្ពស់សមត្ថភាពនិងចំណេះដឹងក្នុងការគ្រប់គ្រងដល់មន្ត្រីសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាមន្ត្រីសាធារណៈដែលតំណាងប្រទេសអាស៊ានទាំងអស់ដែលចូលរួមក្នុងវេទិកានាពេលនេះ (៧)បង្ហាញពីសាមគ្គីភាពរវាងអាស៊ាននៅក្នុងការរៀបចំ



*ប្រភព៖ សណ្ឋាគារសុខាសៀមរាប, ថ្ងៃទី០៤-០៦ ខែកញ្ញា ឆ្នាំ២០១៧*

អនុវត្តនូវប្រព័ន្ធនៃការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈមួយឱ្យមានលក្ខណៈសង្គតិភាពនឹងគ្នាក្នុងកម្រិតមួយដែលអាចទទួលយកបានក្នុងការអនុវត្ត។

ផ្អែកលើលក្ខខណ្ឌនិងធាតុចូលខាងលើ លេខាធិការដ្ឋាន គ.ក.រ ក្រសួងមុខងារសាធារណៈ បានរៀបចំដាក់ចេញនូវសេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលសម្រាប់វិស័យរដ្ឋបាលសាធារណៈកម្ពុជា។

***ចង្កោមសកម្មភាព២.៤ កែលម្អរចនាសម្ព័ន្ធគ្រប់គ្រងបែបបទការងារ និងការអភិវឌ្ឍសមត្ថភាពរបស់នាយកដ្ឋាន ឬអង្គភាពធនធានមនុស្សនៅតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ***

ការអនុវត្តចង្កោមសកម្មភាពនេះ ក្រុមការងារអន្តរក្រសួងដែលដឹកនាំដោយក្រសួងមុខងារសាធារណៈ បានធ្វើការសិក្សាអំពីមុខងារ រចនាសម្ព័ន្ធ និងនីតិវិធី បំពេញការងាររបស់អង្គភាពធនធានមនុស្សនៅខេត្តចំនួន ០៥ ដោយក្នុងខេត្តនីមួយៗ ក្រុមការងារ បានជ្រើស រើសយកក្រុង០១ និងស្រុកចំនួន០២ ជាគោលដៅនៃការសិក្សា រួមមាន៖ ១.ខេត្តកំពង់ធំ (ក្រុងស្ទឹងសែន ស្រុកកំពង់ស្វាយ និងស្រុកប្រាសាទសំបូរ) ២.ខេត្តបាត់ដំបង (ក្រុងបាត់ដំបង ស្រុកឯកភ្នំ ស្រុកភ្នំព្រឹក) ៣.ខេត្ត កោះកុង (ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា ស្រុកស្រែអំបិល) ៤.ខេត្តមណ្ឌលគិរី (ក្រុងសែនមនោរម្យ ស្រុកកោះញែក ស្រុកពេជ្រាដា) និង៥.ខេត្តកណ្តាល (ក្រុងតាខ្មៅ ស្រុកគៀនស្វាយ ស្រុកលើកដែក)។

តាមរយៈការសិក្សានេះ ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋានក្រុមប្រឹក្សាកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំផ្សព្វផ្សាយអំពីរបាយការណ៍នៃការសិក្សា ដោយកំណត់អំពីបញ្ហាប្រឈមនានា ដំណោះស្រាយ ព្រមទាំអនុសាសន៍កែលម្អដល់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

***ចង្កោមសកម្មភាព២.៥ កែលម្អនីតិវិធី និងបែបបទនៃការគ្រប់គ្រងធនធានមនុស្សនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ***

ក្រសួងមុខងារសាធារណៈ បានដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តក្នុងការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាល និងក្រុមប្រឹក្សារាជធានីខេត្តឬរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ ដើម្បីកែសម្រួលការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិសំដៅលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រង បុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ ក្នុងនោះរួមមានដូចជា៖

- អនុក្រឹត្យលេខ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាល និងក្រុមប្រឹក្សារាជធានីខេត្តឬរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ៧៨៨ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីគោលការណ៍ និងនីតិវិធីនៃការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

- សេចក្តីណែនាំលេខ១២៣២ មស.សណន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលខ្លឹមសារនៃសេចក្តីណែនាំលេខ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

ទន្ទឹមនឹងនេះ ក្រុមការងារ ក៏បានរៀបចំដាក់ចេញនូវសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ដោយក្នុងនោះផ្តោតជាសំខាន់ទៅលើការកែលម្អនីតិវិធី និងពង្រឹងការអនុវត្តពាក់ព័ន្ធទៅនឹងការធ្វើផែនការធនធានមនុស្ស ការជ្រើសរើស ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ការឡើងថ្នាក់ ការឡើងឋានន្តរសក្តិ ការតែងតាំងក្នុងមុខតំណែង ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព ការសិក្សាបន្តក្នុងនិងក្រៅប្រទេស ការគ្រប់គ្រងគុណផលនិងការលើកទឹកចិត្ត ការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ឬក្រៅមុខតំណែង ការឈប់សម្រាកពីការងារ ការដាក់វិន័យ ការចោទប្រកាន់តាមផ្លូវតុលាការ ការដោះស្រាយ ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ការចាកចេញពីមុខងារសាធារណៈ មានដូចជា ការបាត់បង់ សម្បទាវិជ្ជាជីវៈ ការលុបឈ្មោះពីក្របខណ្ឌ មរណៈភាព និងការចូលនិវត្តន៍។

### *ចង្កោមសកម្មភាព២.៦ ធ្វើការវិភាគមុខងារ និងត្រួតពិនិត្យប្រតិបត្តិការឡើងវិញនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

ក្រសួងមុខងារសាធារណៈ បានចុះត្រួតពិនិត្យមើលលើការប្រើប្រាស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងសុខាភិបាលកាលពីខែមេសាឆ្នាំ២០១៧ ដែលមានមន្ត្រីរាជការសរុបចំនួន ២៥.៨៦២នាក់ និងបានកំពុងរៀបចំកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាជូនក្រសួងសុខាភិបាល។

ទិន្នន័យដែលប្រមូលបាននេះពីការចុះត្រួតពិនិត្យមើលលើការប្រើប្រាស់មន្ត្រីនេះ នឹងធ្វើការត្រួតពិនិត្យវិភាគឡើងវិញ មុននឹងឈានទៅដល់ការដាក់ឱ្យប្រើប្រាស់ទិន្នន័យនេះជាផ្លូវការទៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា។

### *ចង្កោមសកម្មភាព២.៧ អភិវឌ្ឍ និងពង្រីការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងធន ធានមនុស្សនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ*

ក្រសួងមុខងារសាធារណៈ បានសហការជា មួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) សម្រាប់ក្រសួងសុខាភិបាល ដោយផ្អែកទៅលើទិន្នន័យនៃការប្រើប្រាស់មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា ដែលក្រសួងមុខងារសាធារណៈ បានចុះត្រួតពិនិត្យកាលពីខែមេសា ឆ្នាំ២០១៧ ជាមូលដ្ឋាន។ ការបង្កើតឡើងនូវប្រព័ន្ធនេះ គឺជាការធ្វើវិមជ្ឈការប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) ដល់ក្រសួងស្ថាប័ន ដោយចាប់ផ្តើមអនុវត្តសាកល្បងសម្រាប់ការគ្រប់គ្រងទិន្នន័យមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងក្របខណ្ឌក្រសួងសុខាភិបាល ហើយក្រសួងសុខាភិបាលមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់បញ្ចូលទិន្នន័យ ធ្វើបច្ចុប្បន្នភាពនិងផលិតតារាងបៀវត្សដោយខ្លួនឯងក្រោមការត្រួតពិនិត្យ និងអនុម័តពីក្រសួងមុខងារសាធារណៈ ដោយមានជំនួយបច្ចេកទេសពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ក្នុងករណីការអនុវត្តគម្រោងសាកល្បងនេះទទួលបានភាពជោគជ័យ ក្រសួងមុខងារសាធារណៈនឹងបន្តអនុវត្ត និងពង្រីកទៅដល់គ្រប់ក្រសួងស្ថាប័នទាំងអស់។

*ចង្កោមសកម្មភាព២.៨ បញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ*

ការបញ្ជ្រាបយេនឌ័រ នៅក្នុងក្របខណ្ឌមុខងារសាធារណៈ មានការវិវឌ្ឍន៍ជាវិជ្ជមាន ក្នុងនោះការចូលរួមរបស់ស្ត្រីនៅក្នុងក្របខណ្ឌនៃការរៀបចំគោលនយោបាយយុទ្ធសាស្ត្រជាតិលើកកម្ពស់ស្ត្រីភាពជាអ្នកដឹកនាំក្នុងវិស័យមុខងារសាធារណៈនិងការលើកកម្ពស់ភាពជាតំណាងរបស់ស្ត្រីនៅក្នុងមុខតំណែងធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យមុខងារសាធារណៈជាដើម។ ជាលទ្ធផលសម្រាប់ឆ្នាំ២០១៧ តួលេខស្ត្រីនៅក្នុងវិស័យមុខងារសាធារណៈ និងក្នុងមុខតំណែងគ្រប់គ្រងមានបង្ហាញដូចតារាងខាងក្រោម៖

តារាងទី៣ខាងក្រោមនេះ នឹងបង្ហាញពីចំនួននិងភាគរយស្ត្រីដែលជាមន្ត្រីរាជការស៊ីវិលនៅតាមក្រសួងស្ថាប័ននានា ក្នុងនោះមានចំនួន៣១% (ស្មើនឹង១២,៣៥១នាក់) នៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិមានចំនួន៤៣% (ស្មើនឹង ៧៤,៤១៧នាក់)។ សរុបទិន្នន័យទូទាំងប្រទេស សម្រាប់ស្ត្រីដែលជាមន្ត្រីរាជការស៊ីវិលនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិនិងក្រោមជាតិ មានចំនួន ៤១% (ស្មើនឹងចំនួន ៨៦,៧៦៨ នាក់)។

**តារាងទី៣៖ តារាងស្ថិតិមន្ត្រីរាជការស៊ីវិលជាស្ត្រីសរុបនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

| ល.រ | ក្រសួង ស្ថាប័ន | ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីថ្នាក់ជាតិ | | ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីថ្នាក់ក្រោមជាតិ | | ចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីសរុប | |
|---|---|---|---|---|---|---|---|
| | | ចំនួនស្ត្រី | ភាគរយ | ចំនួនស្ត្រី | ភាគរយ | ចំនួនស្ត្រី | ភាគរយ |
| 1 | ទីស្តីការគណៈរដ្ឋមន្ត្រី | 380 | 24% | 0 | 0% | 380 | 24% |
| 2 | ព្រះបរមរាជវាំង | 71 | 19% | 0 | 0% | 71 | 19% |
| 3 | មហាផ្ទៃ | 339 | 18% | 2,855 | 26% | 3,194 | 25% |
| 4 | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 187 | 30% | 0 | 0% | 187 | 30% |
| 5 | អភិវឌ្ឍជនបទ | 150 | 28% | 251 | 21% | 401 | 24% |
| 6 | ពាណិជ្ជកម្ម | 351 | 27% | 176 | 37% | 527 | 29% |
| 7 | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 1,451 | 27% | 247 | 38% | 1,698 | 28% |
| 8 | អប់រំ យុវជន និងកីឡា | 883 | 27% | 54,511 | 46% | 55,394 | 46% |
| 9 | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 139 | 31% | 98 | 29% | 237 | 30% |
| 10 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 172 | 23% | 380 | 15% | 552 | 17% |
| 11 | ផែនការ | 287 | 33% | 687 | 39% | 974 | 37% |
| 12 | ធម្មការ និងសាសនា | 88 | 22% | 170 | 16% | 258 | 18% |
| 13 | បរិស្ថាន | 211 | 26% | 139 | 7% | 350 | 12% |
| 14 | យុត្តិធម៌ | 166 | 36% | 411 | 24% | 577 | 27% |
| 15 | ប្រៃសណីយ៍ និងទូរគមនាគមន៍ | 263 | 34% | 156 | 33% | 419 | 34% |
| 16 | ព័ត៌មាន | 382 | 36% | 260 | 44% | 642 | 39% |

ប្រភព៖ ទិន្នន័យរបស់ក្រុមការងារយេនឌ័រនៃក្រសួងមុខងារសាធារណៈ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨

| | | | | | | | |
|---|---|---|---|---|---|---|---|
| 17 | វប្បធម៌ និងវិចិត្រសិល្បៈ | 534 | 37% | 407 | 41% | 941 | 39% |
| 18 | ទេសចរណ៍ | 217 | 36% | 200 | 37% | 417 | 37% |
| 19 | សុខាភិបាល | 2,941 | 51% | 10,365 | 53% | 13,306 | 52% |
| 20 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 729 | 25% | 374 | 25% | 1,103 | 25% |
| 21 | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 314 | 38% | 520 | 40% | 834 | 39% |
| 22 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 784 | 28% | 774 | 19% | 1,558 | 23% |
| 23 | ឧស្សាហកម្ម និងសិប្បកម្ម | 142 | 25% | 114 | 21% | 256 | 23% |
| 24 | រ៉ែ និងថាមពល | 104 | 21% | 67 | 18% | 171 | 20% |
| 25 | សាធារណការ និងដឹកជញ្ជូន | 236 | 16% | 414 | 22% | 650 | 19% |
| 26 | កិច្ចការនារី | 194 | 73% | 666 | 88% | 860 | 84% |
| 27 | ធនធានទឹក និងឧតុនិយម | 192 | 23% | 67 | 13% | 259 | 19% |
| 28 | មុខងារសាធារណៈ | 154 | 31% | 108 | 30% | 262 | 31% |
| 29 | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 166 | 24% | 0 | 0% | 166 | 24% |
| 30 | អង្គភាពប្រឆាំងអំពើពុករលួយ | 124 | 30% | 0 | 0% | 124 | 30% |
| | **សរុបរួម** | **12,351** | **31%** | **74,417** | **43%** | **86,768** | **41%** |

ដោយឡែក តារាងទី៤ខាងក្រោមនេះ នឹងបង្ហាញពីចំនួននិងភាគរយស្ត្រីដែលជាមន្ត្រីរាជការស៊ីវិល ដែលមានមុខតំណែងចាប់ពីថ្នាក់ការិយាល័យក្រុង ស្រុក ខណ្ឌ រហូតដល់ថ្នាក់អគ្គនាយក និងថ្នាក់ស្មើនៅតាមក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិមានចំនួន២៤%(ស្មើនឹង៧,០៤៥នាក់) នៃចំនួនស្ត្រីសរុបដែលមានមុខតំណែង(ចំនួនសរុបស្មើនឹង ២៩,៦៩១នាក់)។

**តារាងទី៤៖ តារាងស្ថិតិមន្ត្រីរាជការស៊ីវិលជាស្ត្រីដែលមានមុខតំណែងនៅតាមក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

| ល.រ | ក្រសួង ស្ថាប័ន | សរុបរួម | | ភាគរយ |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ស្ត្រី |
| 1 | ទីស្តីការគណៈរដ្ឋមន្ត្រី | 619 | 128 | 21% |
| 2 | ព្រះបរមរាជវាំង | 223 | 37 | 17% |
| 3 | មហាផ្ទៃ | 2,863 | 819 | 29% |
| 4 | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | 294 | 86 | 29% |
| 5 | អភិវឌ្ឍន៍ជនបទ | 995 | 191 | 19% |
| 6 | ពាណិជ្ជកម្ម | 1,220 | 276 | 23% |
| 7 | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 2,581 | 550 | 21% |
| 8 | អប់រំ យុវជន និងកីឡា | 2,288 | 393 | 17% |
| 9 | ទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 622 | 148 | 24% |

| | | | | |
|---|---|---|---|---|
| 10 | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | 1,366 | 184 | 13% |
| 11 | ផែនការ | 1,085 | 286 | 26% |
| 12 | ធម្មការ និងសាសនា | 411 | 74 | 18% |
| 13 | បរិស្ថាន | 880 | 129 | 15% |
| 14 | យុត្តិធម៌ | 442 | 144 | 33% |
| 15 | ប្រៃសណីយ៍ និងទូរគមនាគមន៍ | 616 | 173 | 28% |
| 16 | ព័ត៌មាន | 979 | 311 | 32% |
| 17 | វប្បធម៌ និងវិចិត្រសិល្បៈ | 988 | 328 | 33% |
| 18 | ទេសចរណ៍ | 711 | 245 | 34% |
| 19 | សុខាភិបាល | 1,063 | 168 | 16% |
| 20 | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | 1,321 | 274 | 21% |
| 21 | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | 932 | 318 | 34% |
| 22 | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | 2,382 | 464 | 19% |
| 23 | ឧស្សាហកម្ម និងសិប្បកម្ម | 685 | 131 | 19% |
| 24 | រ៉ែ និងថាមពល | 491 | 71 | 14% |
| 25 | សាធារណការ និងដឹកជញ្ជូន | 1,264 | 199 | 16% |
| 26 | កិច្ចការនារី | 706 | 612 | 87% |
| 27 | ធនធានទឹក និងឧតុនិយម | 618 | 66 | 11% |
| 28 | មុខងារសាធារណៈ | 450 | 121 | 27% |
| 29 | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | 459 | 90 | 20% |
| 30 | អង្គភាពប្រឆាំងអំពើពុករលួយ | 137 | 29 | 21% |
| | **សរុបរួម** | 29,691 | 7,045 | |
| | **គិតជាភាគរយ(%)** | - | 24% | |

ប្រភព៖ ទិន្នន័យរបស់ក្រុមការងារយេនឌ័រនៃក្រសួងមុខងារសាធារណៈ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៨

តារាងទី៥ខាងក្រោមនេះ នឹងបង្ហាញពីចំនួនស្ត្រីដែលកាន់មុខតំណែងគ្រប់គ្រងនៅតាមរាជធានី ខេត្ត និងស្ថាប័នផ្សេងទៀត ក្នុងនោះរួមមានជា អភិបាល-អភិបាលរង រាជធានី ខេត្ត អភិបាល-អភិបាលរង ក្រុង ស្រុក ខណ្ឌ នាយក-នាយករង រដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ នាយក-នាយករងទីចាត់ការ ប្រធាន-អនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានីខេត្ត ស្មៀន ឃុំ សង្កាត់ ចៅក្រម ព្រះរាជអាជ្ញា អាជ្ញាសាលាក្រឡាបញ្ជី។

**តារាងទី៥៖ តារាងស្ថិតិមន្ត្រីរាជការជាស្ត្រីដែលមានកាន់មុខតំណែងគ្រប់គ្រងនៅតាមរាជធានីខេត្ត និងស្ថាប័នផ្សេងទៀត**

| ល.រ | មុខតំណែង | សរុបរួម | | ភាគរយ |
|---|---|---|---|---|
| | | សរុប | ចំនួនស្ត្រី | ស្ត្រី |
| 1 | អភិបាលរាជធានី ខេត្ត | 25 | 1 | 4% |
| 2 | អភិបាលរងរាជធានី ខេត្ត | 150 | 26 | 17% |

| | | | | |
|---|---|---|---|---|
| 3 | អភិបាលក្រុង ស្រុក ខណ្ឌ | 197 | 7 | 4% |
| 4 | អភិបាលរងក្រុង ស្រុក ខណ្ឌ | 711 | 185 | 26% |
| 5 | នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | 155 | 13 | 8% |
| 6 | នាយករងរដ្ឋបាលសាលា ក្រុង ស្រុក ខណ្ឌ | 249 | 50 | 20% |
| 7 | ស្មៀន ឃុំ សង្កាត់ | 1646 | 235 | 14% |
| 8 | នាយកទីចាត់ការ ប្រធានអង្គភាពលទ្ធកម្ម សាលារាជធានី ខេត្ត | 148 | 16 | 11% |
| 9 | នាយករងទីចាត់ការ អនុប្រធានអង្គភាពលទ្ធកម្មសាលារាជធានី ខេត្ត | 278 | 60 | 22% |
| 10 | ចៅក្រម | 265 | 38 | 14% |
| 11 | ព្រះរាជអាជ្ញា | 180 | 23 | 13% |
| 12 | អាជ្ញាសាលា | 27 | 2 | 7% |
| 13 | ក្រឡាបញ្ជី | 766 | 165 | 22% |

# ផ្នែកទី៤. ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់ឧបត្ថម្ភលើកទឹកចិត្ត

ការកែទម្រង់ប្រព័ន្ធបៀវត្ស ត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗ រួមមាន៖(១)ការដំឡើងបៀវត្ស ត្រូវអនុវត្តសមស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ច និងលទ្ធភាពទ្រទ្រង់បាននៃថវិកាក្នុងន័យធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (២)ការធានាបាននូវសមធម៌ ការបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង(៣)ការធានាសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនិងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

ការអនុវត្តការងារកែទម្រង់ប្រព័ន្ធបៀវត្ស គឺមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធគ្រប់កម្រិតសំដៅលើកកម្ពស់គុណភាពជីវិតរស់នៅរបស់មន្ត្រីរាជការ កម្លាំងប្រដាប់អាវុធ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ស្មៀន មេភូមិ អនុប្រធានភូមិ សមាជិកភូមិ និងមន្ត្រីជាប់កិច្ចសន្យា ព្រមទាំង អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន សំដៅឈានទៅបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង។ ជារួម ការកែទម្រង់បៀវត្ស គិតមកដល់ឆ្នាំ២០១៧នេះ គឺមានការដំឡើងប្រាក់បៀវត្ស ប្រាក់តំបន់ ប្រាក់សោធន៍និវត្តន៍ គួរជាទីមោទន ដូចមាន បង្ហាញក្នុងតារាងខាងក្រោម៖

តារាងទី៦៖ **ការដំឡើងតម្លៃសន្ទស្សន៍បៀវត្សមូលដ្ឋាន**

| ឆ្នាំ / បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|
| សន្ទស្សន៍ | ១.២៦០ | ១.៥២០ | ១.៥២០ | ១.៥២០ | ១.៧០០ | ១.៩០០ |

តារាងទី៧៖ **បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ**

| ឆ្នាំ / បរិយាយ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|
| វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស | ៣៤៤.០០០ | ៤២៤.០០០ | ៥៥២.៨០០ | ៧០០.៥០០ | ៨៥៣.៥០០ |
| វិស័យអប់រំ | ៤០២.៨០០ | ៥៥០.០០០ | ៦៥២.៨០០ | ៨០០.៥០០ | ៩៥៣.៥០០ |
| វិស័យសុខាភិបាល | ៣៦០.០០០ | ៥៥០.០០០ | ៦៥២.៨០០ | ៨០០.៥០០ | ៩៥៣.៥០០ |
| នគរបាលជាតិ | ៣៧៩.៩៣០ | ៤៦០.៩៣០ | ៦២៨.២៧០ | ៧៨៤.៧៣០ | ៩៣៧.៩៧៧ |
| យោធិន | ៣១៥.៩៩០ | ៣៩៦.៩៩០ | ៥៨២.៤៣០ | ៧៣៣.៧៣០ | ៨៨០.៩៧៧ |

## តារាងទី៨៖ **ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់មន្ត្រីជាប់កិច្ចសន្យា ក្រុមប្រឹក្សាគ្រប់ប្រភេទនិងមន្ត្រីភូមិ**

| **ឆ្នាំ** / **បរិយាយ** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** | **២០១៧** |
|---|---|---|---|---|---|
| មន្ត្រីជាប់កិច្ចសន្យា | | | | ៤០០.០០០ | ៥០០.០០០ |
| - ជំនួយការរដ្ឋបាល | ១២០.០០០ | ១២០.០០០ | ១២០.០០០ | | |
| - ជំនួយការបច្ចេកទេស | ១៤០.០០០ | ១៤០.០០០ | ១៤០.០០០ | | |
| - ជំនួយការថ្នាក់ដឹកនាំ | ១៦០.០០០ | ១៦០.០០០ | ១៦០.០០០ | | |
| - អ្នកបច្ចេកទេសជំនាញ | ២០០.០០០ | ២០០.០០០ | ២០០.០០០ | | |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១.០០០.០០០ | ១.០០០.០០០ | ១.០០០.០០០ | ១.០៩០.០០០ | ១.២១០.០០០ |
| សមាជិកក្រុមប្រឹក្សា រាជធានី ខេត្ត | ៨០០.០០០ | ៨០០.០០០ | ៨០០.០០០ | ៨៧០.០០០ | ៩៧០.០០០ |
| ប្រធានក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ៧០០.០០០ | ៧០០.០០០ | ៧០០.០០០ | ៨១០.០០០ | ៩៣៥.០០០ |
| សមាជិកក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ | ៥០០.០០០ | ៥០០.០០០ | ៥០០.០០០ | ៦៥០.០០០ | ៧៥០.០០០ |
| ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ | ១៥០.០០០ | ៣០០.០០០ | ៤០០.០០០ | ៧៥០.០០០ | ៨៨០.០០០ |
| ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | | | ៥៧០.០០០ | | |
| ជំទប់ទី១និងទី២ ចៅសង្កាត់រងទី១និងទី២ | ១២០.០០០ | ២៤០.០០០ | ៣៥០.០០០ | ៥៥០.០០០ | ៦៥០.០០០ |
| ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | | | ៤០០.០០០ | | |
| សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ | ១០០.០០០ | ២០០.០០០ | ៣០០.០០០ | ៤៨០.០០០ | ៥៧០.០០០ |
| ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | | | ៣៥០.០០០ | | |
| ស្មៀនឃុំ-សង្កាត់ | | | ៥៦២ ៨០០ | ៧១០ ៥០០ | ៨៦៣ ៥០០ |
| មេភូមិ | ៦០.០០០ | ១២០.០០០ | ១៦០.០០០ | ២០០.០០០ | ២២៥.០០០ |
| អនុប្រធានភូមិ | ៥០.០០០ | ១០០.០០០ | ១៤០.០០០ | ១៦០.០០០ | ១៨០.០០០ |
| សមាជិកភូមិ | ៤០.០០០ | ៨០.០០០ | ១២០.០០០ | ១៤០.០០០ | ១៦០.០០០ |

## តារាងទី៩៖ **ប្រាក់តំបន់សម្រាប់មន្ត្រីរាជការស៊ីវិលក្នុងវិស័យអប់រំនិងសុខាភិបាល**

| **ល.រ** | **បរិយាយ** | **កម្រិតប្រាក់តំបន់ប្រចាំខែ** | |
|---|---|---|---|
| | | **មុនឆ្នាំ២០១៦** | **ចាប់ពីឆ្នាំ២០១៦** |
| ១ | តំបន់ជួបការលំបាក | ៤០.០០០ | ៨០.០០០ |
| ២ | តំបន់ដាច់ស្រយាលប្រភេទទី១ | ៥០.០០០ | ១០០.០០០ |
| ៣ | តំបន់ដាច់ស្រយាលប្រភេទទី២ | ៦០.០០០ | ១២០.០០០ |

## តារាងទី១០៖ **របបសន្តិសុខសង្គមអប្បបរមាប្រចាំខែសម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន**

| **ឆ្នាំ** / **បរិយាយ** | **២០១៤** | **២០១៥** | **២០១៦** | **២០១៧** |
|---|---|---|---|---|
| អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន | ៩០.០០០ | ៣០០.០០០ | ៣៦០.០០០ | ៤២០.០០០ |

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដំឡើងប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសពជូនគ្រួសារសព មន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាដែលទទួលមរណភាព ដូចខាងក្រោម៖

- ប្រាក់ឧបត្ថម្ភមាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូនត្រូវបានដំឡើងពីចំនួន ៦០០.០០០ រៀល ទៅចំនួន ៨០០.០០០ រៀល សម្រាប់ការសម្រាលបានកូនមួយ
- ប្រាក់ឧបត្ថម្ភនេះ នឹងត្រូវបង្កើនទ្វេគុណ ឬត្រីគុណ ឬច្រើនជាងនេះ ជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីតាមចំនួនកូនដែលបានសម្រាល
- ប្រាក់ឧបត្ថម្ភបុណ្យជូនគ្រួសារសពរបស់មន្ត្រីរាជការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាសម្រាប់ធ្វើបុណ្យតាមប្រពៃណី មានដូចតទៅ៖
    - ទទួលមរណៈភាពដោយជម្ងឺធម្មតាពីចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល ទៅចំនួន ២.០០០.០០០ (ពីលាន) រៀល
    - ទទួលមរណៈភាពក្នុងពេលបំពេញបេសកកម្ម ឬគ្រោះថ្នាក់ការងារពីចំនួន ១.៥០០.០០០ (មួយលានប្រាំសែន) រៀល ទៅចំនួន ៤.០០០.០០០ (បួនលាន) រៀល។

# ផ្នែកទី៥. យន្តការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការ

នៅក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ បានអនុវត្តនូវយន្តការសម្របសម្រួលជំរុញការអនុវត្ត និងកិច្ចសហប្រតិបត្តិការជាមួយគ្រប់ភាគីពាក់ព័ន្ធ រួមមាន៖ ទី១.យន្តការសម្របសម្រួលក្នុងក្របខណ្ឌ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង៣វិស័យ (លេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ) និងទី២. យន្តការសម្របសម្រួលក្នុងក្របខណ្ឌនៃ កិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ។

## ៥.១. យន្តការសម្របសម្រួលក្នុងក្របខណ្ឌលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង៣ វិស័យ

លេខាធិការដ្ឋានកំណែទម្រង់ទាំង៣ បានឯកភាពលើ ផែនការសកម្មភាពរួមនៃកំណែទម្រង់ទាំង៣ ចំនួន០៩ចំនុច និងបានបន្តអនុវត្តផែនការសកម្មភាពរួមទាំងនេះ ដូចមានខាងក្រោម៖

- ពង្រឹងការបើកផ្តល់បៀវត្សនិងប្រាក់លាភការផ្សេងៗទៀតតាមធនាគារឯកជន
- រៀបចំក្របខណ្ឌ និងយន្តការអនុវត្តទណ្ឌកម្មចំពោះការគ្រប់គ្រងធនធានសាធារណៈ
- កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឲ្យមានសមានគតិភាពជាមួយនឹងប្រព័ន្ធដំណើរការការងារថ្មីដែលរួមមាន៖ ផ្នែករដ្ឋបាលបុគ្គលិក ហិរញ្ញវត្ថុ និងបច្ចេកទេសទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធអធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង ស្ថាប័ន ដើម្បីធានាសុខដុមនីយកម្ម
- បង្កើនគុណភាពលើការកសាងសមត្ថភាពនិងការបណ្តុះបណ្តាលទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- រៀបចំក្របខណ្ឌរួមនៃការគ្រប់គ្រងនិងបែងចែកប្រាក់រង្វាន់ពីចំណូលមិនមែនសារពើពន្ធប្រកបដោយសមធម៌និងប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- រៀបចំនិងដាក់ឲ្យដំណើរការនូវយន្តការផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវានៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- រៀបចំនិងដាក់ឱ្យអនុវត្តក្របខណ្ឌវិមជ្ឈការហិរញ្ញវត្ថុ(គោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម ការអនុវត្តការប្រមូលចំណូលផ្ទាល់ ឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ គោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្រ្តថវិកា ការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌ ថវិកាកម្មវិធីពេញលេញនិងអង្គភាពថវិកា
- រៀបចំនិងដាក់ឱ្យអនុវត្តយន្តការស្ថាប័នគាំទ្រភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ ការលើកទឹកចិត្តលើការងារកំណែទម្រង់។

## ៥.២.យន្តការសម្របសម្រួលក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ បានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបណ្តាដៃគូអភិវឌ្ឍទាំងក្របខណ្ឌក្នុងប្រទេស និងតំបន់ ក្នុងនោះរួមមាន៖

ទី១. កិច្ចសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) ក្រោមកម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (DAR Project) កម្មវិធីនេះ ផ្តោតជាសំខាន់លើការផ្តល់សេវាសាធារណៈ និងគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដោយឡែកសម្រាប់ការគាំទ្រដល់ការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ គឺបានជួយរៀបចំគោលការណ៍ណែនាំស្តីពីការផ្តល់សេវាសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (Public Service Guideline for Sub-National Administration) និងការងាររៀបចំដាក់ឲ្យអនុវត្តសាកល្បងនៃប្រព័ន្ធគ្រប់គ្រងគុណផលក្នុងស្រុកមោងឫស្សី និងក្រុងបាត់ដំបង ខេត្តបាត់ដំបង។

ទី២. ធនាគារពិភពលោក (World Bank) បានជួយគាំទ្រផ្នែកបច្ចេកទេសក្នុងការរៀបចំច្បាប់ស្តីពី "ការផ្តល់សេវាសាធារណៈ" ដោយឡែក អង្គការតម្លាភាពកម្ពុជា បានជួយគាំទ្រផ្នែកហិរញ្ញវត្ថុក្នុងការរៀបចំបង្កើតច្រកទ្វារអេឡិចត្រូនិក (Website of Public Service Gateway)។

ទី៣. ក្រសួងមុខងារសាធារណៈ និងសាលាភូមិន្ទរដ្ឋបាល បានសហការជាមួយវិទ្យាស្ថានបណ្តុះបណ្តាលមន្ត្រីរាជការនៃប្រទេសសិង្ហបុរី និងមូលនិធិអន្តរជាតិTemasek ក្នុងការរៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រីជាន់ខ្ពស់ នៅសាលាភូមិន្ទរដ្ឋបាល និងនៅប្រទេសសិង្ហបុរី។

ទី៤. ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន(JICA) បានជួយគាំទ្រលើការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ ដោយផ្តល់ការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាផ្ទាល់នៅប្រទេសជប៉ុន ពាក់ព័ន្ធទៅនឹងការរៀបចំគោលនយោបាយបៀវត្ស។

ទី៥. អង្គការកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍ (OECD) ក្រោមគម្រោងស្តីពីការក្រឡេកមើលការផ្តួចផ្តើមគំនិតរបស់រដ្ឋាភិបាលនៃប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ បានសហការជាមួយក្រសួងមុខងារសាធារណៈ ក្នុងការប្រមូលព័ត៌មាន តាមរយៈការបំពេញកម្រងសំណួរនៃការអង្កេតស្រាវជ្រាវលើប្រធានបទចំនួន៣រួមមាន៖ (១)ការបង្កើតសូចនាករដើម្បីគាំទ្រដល់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងវិស័យសាធារណៈ (២)រដ្ឋាភិបាលបើកចំហរ និងបើកចំហរទិន្នន័យសម្រាប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និង(៣) យុទ្ធសាស្ត្រនៃការគ្រប់គ្រងធនធានមនុស្សនៅក្នុងរដ្ឋបាលថ្នាក់ជាតិ។

ទី៦. អគ្គលេខាធិការអាស៊ានបានគាំទ្រនូវការអនុវត្តគម្រោង ASEAN Public Service Guideline

ទី៧.ក្រសួងមុខងារសាធារណៈសហការជាមួយក្រសួងប្រៃសណីយ៍ ក្នុងការប្រមូល និងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់អំពីព័ត៌មានសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន នៅក្នុងកម្រងព័ត៌មានសេវាសាធារណៈ និងបានដាក់បញ្ចូលក្នុងកម្មវិធីការផ្តល់ព័ត៌មានសេវាសាធារណៈ តាមទូរស័ព្ទស្មាតហ្វូន (Public Service Mobile Application)។ ព័ត៌មាន ដែលត្រូវបានធ្វើបច្ចុប្បន្នភាព រួមមាន ព័ត៌មានអំពីស្តង់ដាសេវាសាធារណៈ (តម្លៃ រយៈពេល នៃការទទួលយកសេវា និងឯកសារតម្រូវ ព្រមទាំងមធ្យោបាយនៃទំនាក់ទំនង និងផ្តល់ព័ត៌មានត្រឡប់ និងបណ្តឹងតវ៉ា។

# ផ្នែកទី៦. យន្តការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ

ក្នុងការជំរុញអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨ ឱ្យបានជោគជ័យតាមការរំពឹងទុក ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំបង្កើតឱ្យមានក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ក្រោមជាតិនៅទូទាំង២៥ រាជធានី ខេត្ត និងដាក់ឱ្យដំណើរការយន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងប្រព័ន្ធរាយការណ៍ ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីបង្គោលស្តីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈដល់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមក្រសួងស្ថាប័ន និងនៅតាមរាជធានី ខេត្ត។




ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងឆ្នាំ២០១៧នេះ យន្តការនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តការងារ គឺធ្វើឡើងតាមរយៈសិក្ខាសាលាចំនួន០៦លើក ផ្តោតទៅលើការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ក្នុងនោះថ្នាក់ជាតិចំនួន០១លើក (រាជធានីភ្នំពេញ) និងថ្នាក់តំបន់ចំនួន០៥លើក (ដែលធ្វើឡើងនៅទីតាំងនៃខេត្តឧត្តរមានជ័យ ប៉ៃលិន ស្ទឹងត្រែង កំពត និងកំពង់ចាម ហើយការរៀបចំសិក្ខាសាលាថ្នាក់តំបន់មួយលើកមានការចូលរួម០៥ រាជធានី ខេត្ត) ដោយមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ សមាសភាពចូលរួម រួមមាន៖ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយករង អគ្គលេខាធិការរង អគ្គាធិការរង ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន(ថ្នាក់ជាតិ) ដោយឡែកនៅថ្នាក់ក្រោមជាតិ សមាសភាពចូលរួម រួមមាន៖ អភិបាលនៃគណៈអភិបាលខេត្ត អភិបាលរងរាជធានី ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្ត អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ និងមន្ទីរជំនាញ អង្គភាពចំណុះរាជធានី ខេត្ត សរុប ១៥៥០ រូប។

ជាមួយគ្នានេះដែរ ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរាជធានី ខេត្ត បានអនុវត្តនូវយន្តការតាមប្រព័ន្ធរាយការណ៍ពីវឌ្ឍនភាពការងារដែលបានអនុវត្តកន្លង (ក្នុងឆ្នាំ ២០១៥-២០១៦-២០១៧) ផ្ញើមកលេខាធិការដ្ឋាន គ.ក.រ ក្រសួងមុខងារសាធារណៈ ដើម្បីបូកសរុប។

គិតត្រឹមខែមីនា ឆ្នាំ២០១៨នេះ របាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨ ដែលលេខាធិការដ្ឋានគ.ក.រ ទទួលបានពីក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័នបានត្រឹមចំនួន១២ក្រសួងស្ថាប័ន (១.ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ២.ក្រសួងធនធានទឹកនិងឧតុនិយម ៣.ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ៤.ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៥.ក្រសួងសុខាភិបាល ៦.ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ៧.ក្រសួងអភិវឌ្ឍជនបទ ៨.ក្រសួងបរិស្ថាន ៩.ទីស្តីការគណៈរដ្ឋមន្ត្រី ១០.ក្រសួងទេសចរណ៍ ១១.ក្រសួងសាធារណការនិងដឹកជញ្ជូន និង១២.ក្រសួងមហាផ្ទៃ)។ ដោយឡែកក្រុមការងារតាមរាជធានី ខេត្ត បានបញ្ជូនរបាយការណ៍វឌ្ឍនភាពមកត្រឹមតែ០៦ខេត្តតែប៉ុណ្ណោះ (១.ខេត្តព្រះសីហនុ ២.ខេត្តកណ្តាល ៣.ខេត្តមណ្ឌលគិរី ៤.ខេត្តតាកែវ ៥.ខេត្តពោធិសាត់ ៦.ខេត្តកំពង់ឆ្នាំង)។ ជាលទ្ធផលនៃរបាយការណ៍ដែលបានផ្ញើមក គឺនៅមានចំនុចខ្វះខាតមួយចំនួនដែលទាមទារឱ្យមានការបំពេញបន្ថែម ឬបំភ្លឺបន្ថែមដើម្បីឱ្យមានលក្ខណៈច្បាស់លាស់ និងអាចវាស់វែងបាន។

ដើម្បីលើកកម្ពស់គុណភាពនិងប្រសិទ្ធភាព នៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋានគ.ក.រ និងអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ ក្រសួងមុខងារសាធារណៈ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី**ប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨** ក្នុងគោលបំណងផ្តល់នូវពុទ្ធិដល់មន្ត្រីបង្គោលនៃក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដើម្បីបានយល់ដឹងអំពី៖ (១)ទស្សនទាននៃការអនុវត្តនូវប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ (២)ការតាមដានត្រួតពិនិត្យ និងវាយតម្លៃដោយផ្អែកទៅលើសូចនាករគោលសមិទ្ធកម្មធៀបទៅនឹងវឌ្ឍនភាពការងារ (៣)ដំណើរ



ទន្លេបាសាក់២, ថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧



ទន្លេបាសាក់២, ថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៧

ការក្នុងការរៀបចំប្រមូលនិងវិភាគទិន្នន័យ ព្រមទាំងការបញ្ចូលទិន្នន័យទៅក្នុងរបាយការណ៍ទៅតាមទម្រង់របាយការណ៍នីមួយៗដែលបានកំណត់ក្នុងឯកសារគោលការណ៍ណែនាំ (៤)ក្របខណ្ឌលទ្ធផលដែលជាឧបករណ៍សម្រាប់តាមដានត្រួតពិនិត្យវឌ្ឍនភាពការអនុវត្តការងារ ដោយក្នុងនោះរួមមាន៖ ការកំណត់សូចនាករផ្ទៀងផ្ទាត់ ប្រភេទនៃសូចនាករកំណត់និយមន័យសូចនាករ និងអ្នកទទួលខុសត្រូវជាដើម (៥)ការរៀបចំដាក់ចេញរបាយការណ៍វឌ្ឍនភាពការងារជាប្រចាំត្រីមាស ឆមាស និងឆ្នាំ ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល (៦)សំដៅចូលរួមការជំរុញការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យកាន់តែប្រសើរ (៧)ចូលរួមសម្របសម្រួល និងផ្តល់នូវរបាយការណ៍សមិទ្ធកម្មធៀបទៅនឹងសូចនាករគោលសមិទ្ធកម្មទាំង៩ដែលបានកំណត់ក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។

ការបណ្តុះបណ្តាលនេះ បានបណ្តុះបណ្តុះដល់ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈមកពី២៩ក្រសួងស្ថាប័នថ្នាក់ជាតិ ក្នុងនោះសមាសភាពចូលរួម សរុបចំនួន*១០០នាក់*។ ដោយឡែក ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅតាមរាជធានី ខេត្ត មានចំនួន១២ខេត្ត ដូចជា៖ខេត្តស្វាយរៀង ព្រៃវែង ពោធិ៍សាត់ កំពង់ឆ្នាំង ត្បូងឃ្មុំ កំពង់ចាម សៀមរាប កំពង់ធំ កំពត ព្រះសីហនុ បាត់ដំបង បន្ទាយមានជ័យ ក្នុងនោះមានសមាសភាពចូលរួម រួមមាន៖ អភិបាល-អភិបាលរងខេត្ត នាយក-នាយករងរដ្ឋបាលសាលាខេត្ត នាយក-នាយករងទីចាត់ធនធានមនុស្ស ប្រធាន-អនុប្រធានមន្ទីរជំនាញ អភិបាល-អភិបាលរង ក្រុង ស្រុក នាយក-នាយករងរដ្ឋបាល ក្រុង ស្រុក និងមន្ត្រីជំនាញ សរុបចំនួន *៦០០ នាក់*។



ខេត្តព្រះសីហនុ, ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៧



ខេត្តសៀមរាប, ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧

# ផ្នែកទី៧. បញ្ហាប្រឈមនៅក្នុងការអនុវត្ត

នៅក្នុងអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ តាមរយៈសិក្ខាសាលាថ្នាក់ជាតិនិងថ្នាក់តំបន់ ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ការបណ្តុះបណ្តាល កិច្ចប្រជុំ ការអង្កេតលើការអនុវត្តជាក់ស្តែង ក្នុងរយៈពេលកន្លងមកនេះ គឺមានជួបប្រទះនូវបញ្ហាប្រឈម មួយចំនួនដែលទាមទារឱ្យមានការចូលរួម ស្វែងយល់ទាំងអស់គ្នា ក្នុងនោះរួមមាន៖

(១) ការផ្សព្វផ្សាយកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិតនៅថ្នាក់ក្រោមជាតិ ហើយក៏នៅមានកង្វះខាតនូវការលើកទឹកចិត្តសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ទន្ទឹមនឹងនេះ បញ្ហាធនធានមនុស្ស ថវិកា និងកង្វះខាតនូវបទដ្ឋានគតិយុត្តសម្រាប់ជំរុញនិងគាំទ្រដល់ការ អនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនៅមានកម្រិត។ ដោយឡែក ការចូលរួមនិងការសហ ការរវាងអង្គភាពនិងអង្គភាព ស្ថាប័ននិងស្ថាប័ន និងដៃគូអភិវឌ្ឍនៅចោទជាបញ្ហានៅឡើយ។

(២) សមត្ថភាពស្ថាប័ននិងធនធានមនុស្សរបស់ក្រសួង ស្ថាប័ន នៅមិនទាន់អាចឆ្លើយតបបាន ពេញលេញទៅនឹងសេចក្តីត្រូវការនៃការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាក់ស្តែងដូចជា៖ ការរៀបចំការពិពណ៌នាមុខតំណែង ហើយការរៀបចំនូវគំរូការពិពណ៌នាមុខតំណែង គឺមានត្រឹមតែកម្រិត គ្រប់គ្រងប៉ុណ្ណោះ ដោយឡែកកម្រិតបច្ចេកទេសវិជ្ជាជីវៈ នៅមិនទាន់បានរៀបចំនៅឡើយទេ ហើយក៏នៅ ពុំទាន់មានស្ថាប័នណាមួយកំណត់ថាការពិពណ៌នាមុខតំណែងដែលរៀបចំឡើងនោះត្រឹមត្រូវឬយ៉ាងនោះ ទេ។ ទន្ទឹមនឹងនេះ ការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មុខតំណែងវិជ្ជាជីវៈ ក៏នៅមានកង្វះខាត សមត្ថភាពនៅក្នុងការរៀបចំអនុវត្តផងដែរ។

(៣) ការកសាងសមត្ថភាពមន្ត្រីរាជការស៊ីវិលក្នុងក្របខណ្ឌរាជរដ្ឋាភិបាល មិនទាន់មានលក្ខណៈ ជាប្រព័ន្ធ និងមិនទាន់មានប្រសិទ្ធភាពឆ្លើយតបទៅនឹងការវិវឌ្ឍរបស់រដ្ឋបាលសាធារណៈ។

(៤) ការវិភាគមុខងាររបស់ក្រសួង ស្ថាប័ន អង្គភាព និងរំហូរការងារក្នុងក្រសួង ស្ថាប័នសាមីនិង អន្តរក្រសួង ស្ថាប័ន សម្រាប់ប្រភេទសេវានីមួយៗមិនទាន់កំណត់បានច្បាស់លាស់ និងកែលម្អឱ្យមាន ប្រសិទ្ធភាពខ្ពស់នៅឡើយ។ ដោយឡែក នីតិវិធីនៃការប្រើប្រាស់ថវិកាមិនទាន់ឆ្លើយតបទាន់ពេលវេលាទៅ នឹងតម្រូវការនៃការអនុវត្តសកម្មភាពក្នុងផែនការដែលបានកំណត់។

(៥) ការផ្សារភ្ជាប់ផ្នែកស្ថាប័ន និងសកម្មភាពកែទម្រង់ទាំងឡាយក្នុងក្របខណ្ឌរាជរដ្ឋាភិ បាលនៅមិនទាន់អនុវត្តឱ្យបានពេញលេញនិងមានប្រសិទ្ធភាព។

(៦) ការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈនិងការលើកកម្ពស់ គុណភាពសេវាសាធារណៈតាម រយៈ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យា (ICT) នៅមានកម្រិតនៅឡើយ។ ជាមួយគ្នានេះផងដែរ ការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យានៅតែមិនទាន់បានធ្វើវិសហមជ្ឈការ ឬវិមជ្ឈការក្នុងការ គ្រប់គ្រង។

# ផ្នែកទី៨. ទិសដៅការងារជាយុទ្ធសាស្ត្រ

ការអនុវត្តការងារកំណែទម្រង់រដ្ឋបាលសាធារណៈជំហានបន្តទៀត ត្រូវកំណត់នូវការងារដែលជាយុទ្ធសាស្ត្រសម្រាប់ឈានទៅសម្រេចបាននូវគោលបំណងរួម ក្នុងនោះត្រូវផ្តោតទៅលើ៖

*១.ការកែលម្អគុណភាពសេវាសាធារណៈ* គឺត្រូវរៀបចំដាក់ចេញនូវច្បាប់ស្តីពីការផ្តល់សេវាសាធារណៈនិងលិខិតបទដ្ឋាននិងនីតិវិធីពាក់ព័ន្ធសម្រាប់អនុវត្តច្បាប់នេះ។ ទន្ទឹមនឹងនេះ ក៏ត្រូវរៀបចំនឹងដាក់ឱ្យអនុវត្តនូវអនុវត្តស្តីពីការវាយតម្លៃនិងផ្តល់រង្វាន់អង្គភាពផ្តល់សេវាសាធារណៈគំរូឬឆ្នើម។ ជាមួយគ្នានេះ ការរៀបចំ និងដាក់ឱ្យអនុវត្តនូវការអនុវត្តច្រកព័ត៌មាននៃការផ្តល់សេវាសាធារណៈ (Public Service Gateway) និងមជ្ឈមណ្ឌលផ្តល់ព័ត៌មានតាមទូរស័ព្ទ (Calling center) គឺជាកិច្ចការសំខាន់ក្នុងការលើកកម្ពស់គុណភាពព័ត៌មាននៃការផ្តល់សេវាសាធារណៈ។

*២.ការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន* នៅក្នុងការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន គឺចាំបាច់ត្រូវអនុវត្តនូវកិច្ចការងារមួយចំនួន ដូចតទៅ៖

- រៀបចំអង្គវិជ្ជាជីវៈរបស់មន្ត្រីរាជការនិងរៀបចំការពិព័ណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ ព្រមទាំងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យមុខងារសាធារណៈ ដើម្បីតម្រង់ទិសដៅទៅរកការគ្រប់គ្រងធនធានមនុស្សផ្អែកលើគុណផលនិងផលិតភាព ប្រាក់រង្វាន់សមិទ្ធកម្ម ការជ្រើសរើសផ្អែកតាមតម្រូវការជាក់ស្តែង ការពិពណ៌នាមុខតំណែង កញ្ចប់ថវិកាដែលផ្តល់ឱ្យក្រសួងស្ថាប័ន និងការតែងតាំងស្របតាមការពិពណ៌នាមុខតំណែងជាដើម សម្រាប់មន្ត្រីរាជការនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ
- រៀបចំ និងដាក់ឱ្យអនុវត្តអនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងគុណផល
- រៀបចំនិងដាក់ចេញនូវព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការគ្រប់គ្រងធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈកម្ពុជា
- វិមជ្ឈការប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យាដោយបញ្ចប់ និងផ្ទេរគម្រោងនាំមុខដល់ក្រសួងសុខាភិបាលមុននឹងបន្តទៅក្រសួងស្ថាប័នដទៃទៀត ក្នុងទិសដៅធ្វើទំនើបកម្មវិស័យមុខងារសាធារណៈ ដើម្បីធានាប្រសិទ្ធភាព ផលិតភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈជូនមន្ត្រីរាជការ
- បង្កើនចំនួនមន្ត្រីរាជការស៊ីវិលជាស្ត្រីនិងស្ត្រីក្នុងមុខតំណែងគ្រប់គ្រងដើម្បីធានាបង្កើនការចូលរួមរបស់ស្ត្រីក្នុងតួនាទីធ្វើសេចក្តីសម្រេច
- បន្តពង្រឹង និងពង្រីកការបណ្តុះបណ្តាលជាប្រព័ន្ធដល់មុខតំណែងដទៃទៀត និងមន្ត្រីក្របខណ្ឌថ្មីក្នុងវិស័យមុខងារសាធារណៈ។

*៣.ការកែទម្រង់ប្រព័ន្ធបៀវត្ស* ត្រូវបន្តរៀបចំការដំឡើងបៀវត្សជូនមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធនិងរៀបចំនូវឯកសារគោលនយោបាយបៀវត្សក្នុងវិស័យសាធារណៈឆ្នាំ២០១៩-២០២៣ ក្នុង

គោលដៅបង្កើនប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗជូនដល់មន្ត្រីរាជការ ដើម្បីបង្កើនគុណភាព ផលិតភាព ទិន្នផល និងគុណផលបំពេញការងាររបស់មន្ត្រីម្នាក់ៗ និងអង្គភាពផ្តល់សេវាសាធារណៈ។

*៤.បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ* ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសយន្តការសម្របសម្រួលផ្នែកបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានកំណែទម្រង់ទាំងបី (PFM, D&D និង PAR) ក្នុងគោលដៅជំរុញ និងលើកកម្ពស់ការចូលរួមគ្រប់ភាគីពាក់ព័ន្ធក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

*៥.បន្តជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ* សំដៅឈានទៅកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ក៏ដូចជាការពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ជាដើម ។

*៦.បង្កើនសកម្មភាពផ្សព្វផ្សាយ និងបណ្តុះបណ្តាលជំនាញដល់មន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ* អំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារកែទម្រង់មុខងារសាធារណៈ និងរដ្ឋបាលសាធារណៈ។

# “កែទម្រង់រស់ មិនកែទម្រង់ស្លាប់”




## យើងចូលរួមអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ

**ក្រសួងមុខងារសាធារណៈ**

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ៖ +៨៥៥-២៣-៨៦៦៥០១
គេហទំព័រ៖ http://www.mcs.gov.kh
បណ្តាញសង្គម៖ http://www.facebook.com/CivilServiceCambodia